

# ឯណាផ្ទះអណ្តើក?

Let's Read
The Asia Foundation



តំណាលថ្ងៃមួយមានអណ្ដើកមួយកំពុងវារកាត់វាលស្មៅ។ វាកំពុងស្វែងរកអ្វីមួយ។

វាខំរំពៃមើលទៅឆ្ងាយផង នៅក្នុងស្មៅផង។



ខ្យងឃើញដូច្នេះ ក៏សួរថា៖ «តើឯងកំពុងរកអ្វីហ្នឹង?»
«ខ្ញុំកំពុងរកផ្ទះរបស់ខ្ញុំ។ តើឯងមានឃើញនៅកន្លែងណាទេ?»



«ទេ ខ្ញុំមិនបានឃើញទេ។ ប៉ុន្តែខ្ញុំនឹងជួយរក!»
ខ្យងក៏ឡើងទំលើស្នូកអណ្តើក។ អណ្តើកក៏បន្តវារទៅមុខទៀត។
ពួកគេខំសម្លឹងមើលហើយមើលទៀត។ ប៉ុន្តែពួកគេនៅតែ
មិនឃើញផ្ទះសោះ។



ចាបឃើញក៏សួរ៖ «តើឯងកំពុងរកអ្វីមែនទេ?»

«យើងកំពុងរកផ្ទះរបស់អណ្ដើក។ តើឯងមានឃើញនៅកន្លែងណាទេ?»

«ទេ ខ្ញុំមិនបានឃើញទេ។ ប៉ុន្តែខ្ញុំនឹងជួយរក!»



ចាបក៏ទទះស្លាបហើរចេញទៅ។
អណ្ដើកក៏ស្រែកហៅ៖ «ឯងហើរលឿនពេកហើយ!»
«មិនអីទេ! អីចឹងខ្ញុំនឹងឡើងជិះលើស្នូករបស់ឯងដែរ។»
អណ្ដើកក៏វារទៅមុខទៀត ដោយមានខ្យង និងចាប ទំលើស្នូក
វា។ ពួកគេខំសម្លឹង មើលហើយមើលទៀត។ ប៉ុន្តែពួកគេនៅតែ
មិនឃើញផ្ទះសោះ។



អណ្ដើកមាសឃើញក៏សួរថា៖ «តើឯងកំពុងរកអ្វីមែនទេ?»
«យើងកំពុងរកផ្ទះរបស់អណ្ដើក។ តើឯងមានឃើញនៅកន្លែងណាទេ?»



«ទេ ខ្ញុំមិនបានឃើញទេ។ ប៉ុន្តែខ្ញុំនឹងជួយរក!» អណ្ដើកមាស ក៏លោតឡើងលើស្នូករបស់អណ្ដើក។ អណ្ដើកក៏ដើរបន្តទៀត ដោយមានខ្យង ចាប និងអណ្ដើកមាសនៅលើស្នូករបស់វា។ ពួកគេរកហើយរកទៀត ប៉ុន្តែពួកគេនៅតែមិនឃើញផ្ទះសោះ។ ខ្យល់ក៏ចាប់ផ្ដើមបក់។



កណ្ដុរឃើញក៏សួរ៖ «តើឯងកំពុងរកអ្វីមែនទេ?»
«អូ! បងកណ្ដុរ! ខ្ញុំកំពុងរកផ្ទះរបស់ខ្ញុំ។ តើបងមានឃើញនៅកន្លែងណាទេ?»
«ទេ ខ្ញុំមិនបានឃើញទេ។ ប៉ុន្តែខ្ញុំនឹងជួយរក!»



កណ្តុរលោតឡើងលើស្នូកអណ្តើក។
អណ្តើកវារទៅមុខទៀត ដោយមានខ្យង ចាប អណ្តើកមាស និង
កណ្តុរ ទំលើស្នូកវា។ ពួកគេខំប្រឹងរកមើលហើយមើលទៀត។
ប៉ុន្តែពួកគេនៅតែមិនឃើញផ្ទះសោះ។
ខ្យល់បក់ស្លឹកឈើផុតពីដី ហើយវិលជុំវិញអណ្តើក។



ខ្យល់បក់កាន់តែខ្លាំងទៅៗ។ មេឃប្រែងងឹត។ អណ្ដើកតនិយាយ
ទាំងអស់សង្ឃឹមថា «តើផ្ទះខ្ញុំនៅឯណា?»
ផ្គរលាន់ខ្លាំងៗ ផ្លេកបន្ទោរចាំងផ្លេកៗពីចម្ងាយ។ តក់ តក់ តក់
ភ្លៀងធ្លាក់មកហើយ។
ខ្យង ចាប អណ្ដើកមាស និងកណ្ដុរក៏ស្រែកបន្ទរថា «តើផ្ទះរបស់
អណ្ដើកនៅឯណា?»



ខ្យល់កាន់តែបក់ខ្លាំង។ ខ្យង ចាប អណ្តើកមាស និងកណ្តុរ ត្រូវខ្យល់ប៉ើងធ្លាក់ពីលើស្នូកអណ្តើក។



«អឺ!» អណ្តើកស្រែកដោយភ័យខ្លាច។ បន្ទាប់មក វាក៏លឹបខ្លួន
ចូលទៅក្នុងស្នូករបស់ខ្លួន។
នៅខាងក្នុងស្នូក អណ្តើកកក់ក្តៅស្រួលខ្លួនមែនទែន។
«អូហ៍! នេះគឺជាផ្ទះរបស់ខ្ញុំហើយ។»



«អូហ៍! នេះហើយជាផ្ទះរបស់អណ្ដើក។»



# Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Tortoise Finds His Home*, Published by Book Dash, © Book Dash. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/
Contributing translators: Somey Chheang and Heam Sopheatra